ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

**សាលក្រមព្រហ្មទណ្ឌ**
**លេខ ១១៦/១៧ ក្រ២ "ខ"**
**ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤**
សំណុំរឿងព្រហ្មទណ្ឌលេខ១៣៦០
ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣
សំណុំរឿងស៊ើបសួរលេខ១១៣១ ម.ខ
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣
សំណុំរឿងជំនុំជម្រះលេខ២៨០
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ០៨ និង ៣០នាទីព្រឹក នៅសាលសវនាការទី២ ដោយមានសមាសភាព៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តព្រះសីហនុ

**ចៅក្រមប្រឹក្សា**

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌ **១៣៦០** ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានជនជាប់ចោទ៖

**១-**ឈ្មោះ [redacted] **ឃឹម** ភេទប្រុស អាយុ ២៤ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ថ្នាក់ទី២ មានទីកន្លែងកំណើតនៅភូ[redacted] ខេត្តព្រៃវែង មានទីលំនៅមុនពេលឃុំខ្លួននៅភូមិរាម ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] សេងហាន គ្មានកូន ឪពុកឈ្មោះ [redacted] សន "រ" ម្តាយឈ្មោះ [redacted] សំរឿន "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **"គ្មាន"**។ **(ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០៨១ ជ.ប.ឃ.ខ/ឈ/២៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣)**

**២-**ឈ្មោះ [redacted] ***ភ័កត្តិ*** ហៅ **នីត** ភេទប្រុស អាយុ ១៤ឆ្នាំ កើតឆ្នាំ២០០៩ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ ថ្នាក់ទី៥ មានទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តព្រៃវែង មានទីលំនៅមុនពេលឃុំខ្លួននៅភូមិរាម ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នៅលីវ ឪពុកឈ្មោះ [redacted] វង "រ" ម្តាយឈ្មោះ[redacted] ណេត "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **"គ្មាន"**។ **(ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០៨២ ជ.ប.ឃ.ខ/ឈ/២៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣)**

**៣-**ឈ្មោះ [redacted] ***ភ័ន់ថា*** ហៅ **វីរៈ** ភេទប្រុស អាយុ ២៤ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ថ្នាក់ទី៧ មានទីកន្លែងកំណើតនៅ[redacted] ខេត្តព្រៃវែង មានទីលំនៅមុនពេលឃុំខ្លួននៅភូមិរាម ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] ស្រីណុច មានកូនចំនួន ០២នាក់ ឪពុកឈ្មោះ មិនស្គាល់ឈ្មោះ "ស" ម្តាយឈ្មោះ [redacted] យ៉ែន "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **"គ្មាន"**។ **(ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០៨៣ ជ.ប.ឃ.ខ/ឈ/២៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣)**



Scanned with CamScanner

**៤-ឈ្មោះ** [redacted] **ដារ៉ូ ឬ តូច ដារ៉ូ** ហៅ **ពៅ** ភេទប្រុស អាយុ ២៤ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ កម្រិតវប្បធម៌ថ្នាក់ទី៧ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តស្វាយរៀង មានទីលំនៅមុនពេលឃុំខ្លួននៅការដ្ឋានសំណង់មួយកន្លែងម្តុំឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] ស្រីរី ឪពុកឈ្មោះ តូច សម្បត្តិ "ស" ម្តាយឈ្មោះ [redacted] ស្រីនាង "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **"គ្មាន"**។ **(ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០៨៤ ដ.ប.ឃ.៦/ឈ/២៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣)**

**៥-ឈ្មោះ** [redacted] **វស្សី** ភេទប្រុស អាយុ ២២ឆ្នាំ កើតឆ្នាំ២០០១ ជនជាតិខ្មែរ មុខរបរ រត់ម៉ូតូកង់បី កម្រិតវប្បធម៌ ថ្នាក់ទី១២ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅមិនពិតប្រាកដ ក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៅលីវ ឪពុកឈ្មោះ [redacted] សាត់ "រ" ម្តាយឈ្មោះ [redacted] សេង "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **"គ្មាន"**។ **(ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០៨៥ ដ.ប.ឃ.៦/ឈ/២៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣)**

ត្រូវបានដាក់ក្រោមការពិនិត្យពីបទ **ឆបោក** និងបទ **ស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ** ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៧៧**, មាត្រា **៣៧៨** និងមាត្រា **៥០៨** នៃក្រមព្រហ្មទណ្ឌ។

## មេធាវីជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **១១២៣** អ.យ.ង/២៣ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ របស់ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **១៣២** អ.យ.ង/២៤ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **០៦៧** ដ.ស.រ.ជ/ឈ/២៤ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តព្រះសីហនុ។

**-បានឃើញ** ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ **១១១៤** ត.ព.រ/២៤ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុដែលប្តឹងមកតុលាការ

កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១០ និង ៣០ នាទីព្រឹក នៅចំនុចភូមិសាស្ត្រក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ **មានករណីស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ(ក្លែងធ្វើព្រះសង្ឃ) និងឆបោក** មួយបង្កឡើយដោយឈ្មោះ [redacted] **ឃីម** ភេទប្រុស, ឈ្មោះ [redacted] **ភ័កក្តី** ហៅ **នីត** ភេទប្រុស, ឈ្មោះ [redacted] **វ៉ាន់ថា** ហៅ **វីរៈ** ភេទប្រុស, ឈ្មោះ [redacted] **ដារ៉ូ ឬ តូច ដារ៉ូ** ហៅ **ពៅ** ភេទប្រុស និងឈ្មោះ [redacted] **វស្សី** ភេទប្រុស។ ដំបូងឈ្មោះ [redacted] **ដារ៉ូ** ឬ [redacted] **ដារ៉ូ** ហៅ **ពៅ** និងឈ្មោះ [redacted] **លៀក** (អនីតិជនអាយុ ១២ឆ្នាំ) បានស្លៀកពាក់ក្លែងខ្លួនធ្វើជាព្រះសង្ឃដើម្បីដើរបិណ្ឌបាត់បច្ច័យពីពុទ្ធបរិស័ទក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយមានឈ្មោះ [redacted] **វស្សី** មុខរបររត់ម៉ូតូកង់បី (ផាស់អាប់) ធ្វើសកម្មភាពដឹកពួកគេទាំង ០២នាក់ ដោយមួយថ្ងៃបានថ្លៃឈ្នួលចំនួន៥០,០០០ (ប្រាំម៉ឺន)រៀល។ ចំណែកឯឈ្មោះ [redacted] **ឃីម**, ឈ្មោះ [redacted] **វ៉ាន់ថា** ហៅ **វីរៈ** និងឈ្មោះ [redacted] **ភ័កក្តី** ហៅ **នីត** បានធ្វើសកម្មភាពស្លៀកពាក់ក្លែងខ្លួនធ្វើជាព្រះសង្ឃដើម្បី ដើរបិណ្ឌបាតបច្ច័យពីពុទ្ធបរិស័ទនៅក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដូចគ្នាដោយឈ្មោះ [redacted] **ឃីម** បានជួលម៉ូតូកង់បីមួយគ្រឿង ដើម្បីធ្វើជាមធ្យោបាយក្នុងការធ្វើដំណើរ។ លុះដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ មានប្រជាពលរដ្ឋនៅផ្សារលើមានការសង្ស័យទើបបានរាយការណ៍ជូនសមត្ថកិច្ចធ្វើការស្រាវជ្រាវឃាត់ខ្លួនបានជនសង្ស័យទាំងអស់ខាងលើព្រមទាំងដកហូតបានវត្ថុតាងមួយចំនួន រួមមានម៉ូតូកង់បីឥណ្ឌាចំនួន ០១គ្រឿង, អាវកាក់លោក(ហង្សាក់) ចំនួន ០៧, ស្បង់ចីពរ ចំនួន ០៧, ចង្កេះ ចំនួន ០៧, ឆត្រ ចំនួន ០៧, បាតលោក ចំនួន ០៥, កាបូបស្ពាយពណ៌ខ្មៅ ចំនួន ០១, កាបូបដៃបុរសពណ៌ខ្មៅចំនួន ០២, ប្រាក់ចំនួន ២០៥,០០០រៀល និងទូរស័ព្ទដៃចំនួន ០៥គ្រឿង។



Scanned with CamScanner

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ឃឹម** បានឆ្លើយថា ៖ នៅអំឡុងខែមិថុនា ឆ្នាំ២០២៣ ខ្លួនបានទិញអ័ត្រចំនួន០១, បាតចំនួន០១, ស្បង់ចីពរចំនួន ១, អាវកាកលោក(ហង្សាក់) ចំនួន០១ និងថង់យាមចំនួន ០១ ពីខេត្តព្រៃវែងរួចយកមកខេត្តព្រះសីហនុ។ បន្ទាប់មកខ្លួនបានក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងផ្ទះរបស់ប្រជាពលរដ្ឋនៅម្តុំវត្តក្រោមម្តុំវិមានឯករាជ្យ និងនៅម្តុំត្រីដូហ្ស៊ីន ដោយដើរបិណ្ឌបាតម្តងៗបានប្រាក់ពី ៦ម៉ឺនរៀល ទៅ ៩ម៉ឺនរៀលក្នុង០១ថ្ងៃ។ ពេលដើរបិណ្ឌបាតរួចហើយខ្លួនមកស្នាក់នៅបន្ទប់ជួលវិញ។ ខ្លួនបានក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងតាមផ្ទះរបស់ប្រជាពលរដ្ឋ រៀងរាល់ពីរ ទៅបីថ្ងៃម្តង ដោយមិនបានដើរបិណ្ឌបាតរាល់ថ្ងៃឡើយ។ ចំពោះមូលហេតុដែលខ្លួនក្លែងធ្វើជាព្រះសង្ឃដើរបិណ្ឌបាតបែបនេះ ដោយសារតែគ្រួសារខ្លួនមានជីវភាពខ្វះខាតហើយឪពុកខ្លួនឈឺត្រូវបញ្ចូលឈាមរាល់ខែ ទើបខ្លួនមិនមានប្រាក់គ្រប់គ្រាន់ដើម្បីព្យាបាលជំងឺឪពុក ហើយក៏បែកគំនិតក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងផ្ទះតែម្តង។ ក្រៅពីដើរបិណ្ឌបាត ខ្លួនបានរត់កង់បី និងធ្វើជាកម្មករអូសឥវ៉ាន់ឱ្យគេនៅទំនប់រលក។ ចំពោះលុយដែលខ្លួនរកបានដោយដើរបិណ្ឌបាត រត់កង់បី និងអូសឥវ៉ាន់ឱ្យគេ ខ្លួនទុកផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃខ្លះ និងបានផ្ញើរឱ្យគ្រួសារនៅស្រុកកំណើតដើម្បីមើលជំងឺឪពុកខ្លះ។ ខ្លួនដើរបិណ្ឌបាតមានគ្នាចំនួន ០៣នាក់ រួមមានឈ្មោះ [redacted] **ភក្តី** ហៅ **នីត** និងឈ្មោះ [redacted] **វ៉ាន់ថា** និង ខ្លួន ដោយថ្ងៃខ្លះដើរបិណ្ឌបាតជុំគ្នាថ្ងៃខ្លះដើរបិណ្ឌបាតបែកផ្លូវគ្នា ប៉ុន្តែពួកខ្លួនបានស្នាក់នៅជាមួយគ្នា។ រីឯឈ្មោះ [redacted] **ដារ៉ូ** និងឈ្មោះ [redacted] **រស្មី** ខ្លួនមិនស្គាល់ទេ ហើយក៏មិនដែលបានដើរបិណ្ឌបាតជាមួយគ្នាដែរ។

-ជនជាប់ចោទឈ្មោះ [redacted] **ភ័កក្តី** ហៅ **នីត** បានឆ្លើយថា ៖ នៅអំឡុងខែតុលា ឆ្នាំ២០២៣ ខ្លួនបានសុំពូឈ្មោះ [redacted] **ឃឹម** ធ្វើជាព្រះសង្ឃក្លែងក្លាយដើរបិណ្ឌបាតនៅតាមផ្លូវ និងនៅតាមផ្ទះរបស់ប្រជាពលរដ្ឋជាមួយគាត់ ហើយពូឈ្មោះ [redacted] **ឃឹម** បានយល់ព្រម ដោយគាត់បានទៅទិញអ័ត្រចំនួន០១, បាតចំនួន០១, ស្បង់ចីពរចំនួន០១, អាវកាកលោក(ហង្សាក់) ចំនួន០១ និងថង់យាមចំនួន០១ ពីស្រុកកំណើតនៅខេត្តព្រៃវែងមកឱ្យខ្លួន។ បន្ទាប់មកខ្លួនបានក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងតាមផ្ទះរបស់ប្រជាពលរដ្ឋនៅម្តុំក្បែផ្សារលើ ដោយដើរបិណ្ឌបាតបានប្រាក់ពី ៨ម៉ឺនរៀល ទៅ ១០ម៉ឺនរៀល ក្នុង ០១ថ្ងៃ។ ពេលដើរបិណ្ឌបាតរួច ខ្លួនមកស្នាក់នៅបន្ទប់ជួលវិញ។ ខ្លួនបានក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងផ្ទះរបស់ប្រជាពលរដ្ឋរៀងរាល់ ០២ ទៅ ០៣ថ្ងៃដើរបិណ្ឌម្តង មិនមែនដើរបិណ្ឌបាតរាល់ថ្ងៃទេ ព្រោះខ្លាចគេចាប់។ មូលហេតុដែលខ្លួនក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងផ្ទះបែបនេះដោយសារតែខ្លួនមិនមានការងារធ្វើព្រោះខ្លួនមានអាយុទើបតែ ១៤ឆ្នាំ គេមិនហ៊ានទទួលឱ្យធ្វើការ ហើយគ្រួសារខ្លួនមានជីវភាពខ្វះខាត ឪពុកម្តាយបានលែងលះគ្នាមិនមានអ្នកជួយផ្គត់ផ្គង់ដល់ខ្លួន។ ម្យ៉ាងវិញទៀតយាយតានៅស្រុកដែលខ្លួនរស់នៅជាមួយ ពួកគាត់ចាស់ជរា និងមានជំងឺ ដោយលោកតាខ្វះឈាមត្រូវបញ្ចូលឈាមរាល់ខែ។ ក្រៅពីក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាត ខ្លួនមិនមានការងារផ្សេងទេហើយខ្លួនក៏មិនដែលដើរលួចឆក់ប្លន់គេដែរចំណែកលុយដែលរកបានខ្លួនទុកផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ និងផ្ញើឱ្យលោកតាខ្លះដើម្បីឱ្យគាត់ទុកព្យាបាលជំងឺ។ ខ្លួនមិនធ្លាប់បួសរៀនបែបព្រះពុទ្ធសាសនាទេ។ ពួកខ្លួនក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតមានគ្នា ០៣នាក់មានឈ្មោះ [redacted] **វ៉ាន់ថា** ហៅ **នីត**, ឈ្មោះ [redacted] **ឃឹម** និងខ្លួន ដោយថ្ងៃខ្លះដើរបិណ្ឌបាតជុំគ្នា និងថ្ងៃខ្លះដើរបិណ្ឌបាតបែកផ្លូវគ្នា ដោយខ្លួនច្រើនដើរជាមួយឈ្មោះ [redacted] **វ៉ាន់ថា** ប៉ុន្តែពួកខ្លួនបានស្នាក់នៅជាមួយគ្នា។ ចំពោះឈ្មោះ [redacted] **ដារ៉ូ** និងឈ្មោះ [redacted] **រស្មី** ខ្លួនមិនដែលស្គាល់ទេ ហើយក៏មិនដែលបានដើរបិណ្ឌបាតជាមួយគ្នាដែរ។ ពេលសមត្ថកិច្ចឃាត់ខ្លួនគេបានដកហូតពីខ្លួននូវទូរស័ព្ទចំនួន ០១គ្រឿង ម៉ាក IPHONE ៧, អ័ត្រចំនួន០១, បាតចំនួន០១, ស្បង់ចីពរចំនួន០១, អាវកាកលោក(ហង្សាក់) ចំនួន០១, ថង់យាមចំនួន០១ និងលុយខ្មែរចំនួន ១០ម៉ឺនរៀល។

-ជនជាប់ចោទឈ្មោះ [redacted] **វ៉ាន់ថា** ហៅ **វីរៈ** បានឆ្លើយថា ៖ ខ្លួនទើបតែមករស់នៅខេត្តព្រះសីហនុ បានរយៈពេលប្រហែលជាង ០១ខែ និងបានក្លែងខ្លួនធ្វើជាព្រះសង្ឃក្លែងក្លាយដើរបិណ្ឌបាតបានប្រហែល ១០ថ្ងៃមុនពេលសមត្ថកិច្ចឃាត់ខ្លួន។ កាលអំឡុងចុងខែវិច្ឆិកា ឆ្នាំ២០២៣ ខ្លួនបានសុំពូថ្លៃឈ្មោះ [redacted] **ឃឹម** ធ្វើជាព្រះសង្ឃក្លែងក្លាយដើរបិណ្ឌបាតនៅតាមផ្លូវ និងតាមផ្ទះរបស់ប្រជាពលរដ្ឋជាមួយគាត់ ហើយពូខ្លួនក៏បានយល់ព្រម បន្ទាប់មកខ្លួនបានទៅទិញអ័ត្រចំនួន០១, បាតចំនួន០១, ស្បង់ចីពរចំនួន០១, អាវកាក់លោក (ហង្សាក់) ចំនួន០១ និងថង់យាមចំនួន០១ ពីផ្សារលើក្នុងក្រុងព្រះសីហនុ ក្នុងក្រុងព្រះសីហនុ ហើយខ្លួនបានក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងតាម



Scanned with CamScanner

ផ្ទះរបស់ប្រជាពលរដ្ឋចាប់ពីម្តុំគោពីរមកម្តុំក្បែរផ្សារលើ ដោយដើរបិណ្ឌបាតចន្លោះពីម៉ោង ០៨ ដល់ម៉ោង ១០ព្រឹក ហើយបិណ្ឌបាតបានប្រាក់ចន្លោះពី ៥ម៉ឺនរៀល ទៅ ៦ម៉ឺនរៀលក្នុង ០១ថ្ងៃ។ ពេលដើរបិណ្ឌបាតបានរយៈពេល ៧ថ្ងៃ ខ្លួនបានទៅស្រុកកំណើត។ ខ្លួនបានមកខេត្តព្រះសីហនុវិញ នៅអំឡុងដើមខែធ្នូ ហើយដើរបិណ្ឌបាតបាន ៣ថ្ងៃក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន។ ខ្លួនបានក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងផ្ទះរបស់ប្រជាពលរដ្ឋរយៈពេល ០២ ទៅ ០៣ថ្ងៃម្តង។ មូលហេតុដែលខ្លួនក្លែងធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងតាមផ្ទះរបស់ប្រជាពលរដ្ឋ ព្រោះតែគ្រួសារខ្លួនមានជីវភាពខ្វះខាត ប្រពន្ធកូនខ្ចីរយៈពេល ០៥ខែ ថែមទាំងមានកូនតូចអាយុ ០៣ឆ្នាំ និងជាប់បំណុលធនាគារចំនួន ៣,០០០ ដុល្លារអាមេរិក ព្រមទាំងជួយបង់ធនាគារម្តាយចំនួន ២០០០ដុល្លារអាមេរិក។ ក្រៅពីក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាត ខ្លួនមិនមានការងារផ្សេងទេ ហើយខ្លួនក៏មិនដែលដើរលួចឆក់ប្លន់គេដែរ ចំណែកលុយដែលរកបានខ្លួនទុកផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃខ្លះ និងផ្ញើរឱ្យប្រពន្ធទុកបង់ធនាគារខ្លះ និងជួយបង់ធនាគារឱ្យម្តាយខ្លះ។ ខ្លួនមិនធ្លាប់បួសរៀនបែបព្រះពុទ្ធសាសនាទេ។ ពួកខ្លួនក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតមានគ្នាចំនួន ៣នាក់ រួមមានមានឈ្មោះ [redacted] **ភ័កក្តី**, ឈ្មោះ [redacted] **ឃើម** និងខ្លួន ដោយថ្ងៃខ្លះដើរបិណ្ឌបាតជុំគ្នា និងថ្ងៃខ្លះដើរបិណ្ឌបាតបែកផ្លូវគ្នា ដោយខ្លួនច្រើនដើរបិណ្ឌបាតតែម្នាក់ឯង ប៉ុន្តែស្នាក់នៅបន្ទប់ជាមួយគ្នាទាំង ០៣នាក់។ ចំពោះឈ្មោះ [redacted] **ដារ៉ូ** និងឈ្មោះ [redacted] **វស្សី** ខ្លួនមិនធ្លាប់ស្គាល់ពីមុនមកទេ ហើយក៏មិនដែលបានដើរ បិណ្ឌបាតជាមួយគ្នាដែរ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួន គេបានដកហូតនូវទូរស័ព្ទចំនួន ០១គ្រឿងម៉ាក OPPO ពណ៌ខ្មៅ, ឆ័ត្រចំនួន០១, បាតចំនួន០១, ស្បង់ចីពរចំនួន ០១, អាវកាកណោក(ហង្សាក់) ចំនួន០១, ថង់យាមចំនួន០១ និងលុយខ្មែរចំនួន ៤ម៉ឺនរៀល។

-ជនជាប់ចោទឈ្មោះ [redacted] **ដារ៉ូ** ឬ [redacted] **ដារ៉ូ** ហៅ **ពៅ** បានឆ្លើយថា ៖ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ ខ្លួនបានទៅរើសសម្ភារៈព្រះសង្ឃនៅក្បែចេតិយនៅក្នុងវត្តលើមានបាតចំនួន០១, ស្បងចីពរចំនួន០១, អាវកាក់ណោក (ហង្សាក់) ចំនួន០១ និងថង់យាមចំនួន០១ រួចខ្លួនបានទៅទិញឆ័ត្រ១។ បន្ទាប់មកនៅថ្ងៃទី០២ និងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ ខ្លួនបានក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងតាមផ្ទះរបស់ប្រជាពលរដ្ឋពីម្តុំផ្សារឃ្លាំងលើ ទៅម្តុំរោងចក្រញវស្តាដោយដើរបិណ្ឌបាតបានប្រាក់ចំនួន ១០ម៉ឺនរៀល និងថ្ងៃទី២ បានប្រាក់ចំនួនជាង ១០ម៉ឺនរៀល។ មូលហេតុដែលខ្លួនក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតាមផ្លូវ និងផ្ទះរបស់ប្រជាពលរដ្ឋដោយសារតែខ្លួនមានជីវភាពខ្វះខាតមិនមានលុយជិះឡានទៅស្រុកកំណើតជូនប្រពន្ធទៅពេទ្យ ព្រោះប្រពន្ធខ្លួនកំពុងមានផ្ទៃពោះ និងមានសុខភាពខ្សោយ និងត្រូវជូនម្តាយទៅពេទ្យផងដែរព្រោះម្តាយមានជំងឺប្រចាំកាយត្រូវទៅពិនិត្យ និងទិញថ្នាំរាល់ខែ។ ក្រៅពីក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាត ខ្លួនមានមុខរបរជាកម្មករសំណង់។ ខ្លួនមិនធ្លាប់បួសរៀនបែបព្រះពុទ្ធសាសនាទេ ខ្លួនក្លែងធ្វើជាព្រះសង្ឃដើរបិណ្ឌបាតតែម្នាក់ឯងប៉ុណ្ណោះមិនមានគ្នាទេ។ ឈ្មោះ [redacted] **វស្សី** ជាអ្នករត់កងបី គាត់គ្រាន់តែជាអ្នកដឹកខ្លួនទៅដើរបិណ្ឌបាតប៉ុណ្ណោះ ដោយខ្លួនបានខលហៅគាត់ឱ្យមកយកខ្លួនទៅដាក់នៅម្តុំផ្សារឃ្លាំងលើ នៅពេលខ្លួនស្លៀកពាក់ស្បង់ចីពររួចរាល់។ ខ្លួនឱ្យប្រាក់ទៅឈ្មោះ [redacted] **វស្សី** មួយថ្ងៃចំនួន ៥ម៉ឺនរៀល បន្ទាប់ពីដើរបិណ្ឌបាតរួច។ ចំពោះឈ្មោះ [redacted] **វ៉ាន់ថា**, ឈ្មោះ [redacted] **ឃើម** និងឈ្មោះ [redacted] **ភ័កក្តី** ខ្លួនមិនដែលស្គាល់ពីមុនមកទេ ហើយក៏មិនដែលបានដើរបិណ្ឌបាតជាមួយគ្នាដែរ ខ្លួនទើបតែស្គាល់ពួកគាត់នៅពេលសមត្ថកិច្ចឃាត់ខ្លួនមកជាមួយគ្នា។ នៅពេលគេឃាត់ខ្លួន គេបានដកហូតពីខ្លួននូវ ទូរស័ព្ទដៃចំនួន ០១ទូរស័ព្ទ គ្រឿងម៉ាក OPPO ពណ៌ខៀវ, ឆ័ត្រចំនួន០១, បាតចំនួន ០១, ស្បង់ចីពរចំនួន០១, អាវកាក់ណោក(ហង្សាក់)ចំនួន០១, ថង់យាមចំនួន០១ និងលុយខ្មែរចំនួន ១៦ម៉ឺនរៀល។

-ជនជាប់ចោទឈ្មោះ [redacted] **វស្សី** បានឆ្លើយថា ៖ សមត្ថកិច្ចបានឃាត់ខ្លួននៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ នៅពេលខ្លួនកំពុងតែបើកកងបីដឹកឈ្មោះ [redacted] **ដារ៉ូ** ទៅជិះតាក់ស៊ីទៅស្រុក នៅស្នាច់ដែងម្តុំមុខព្រលានយន្តហោះ ដោយដឹកដល់ជិតព្រលានយន្តហោះក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ពេលសមត្ថកិច្ចឆែកឆេរកងបីរបស់ខ្លួនបានរកឃើញឆ័ត្រចំនួន០១, បាតចំនួន០១, ស្បង់ចីពរចំនួន០១, អាវកាកណោក(ហង្សាក់) ចំនួន០១, ថង់យាមចំនួន០១ ជារបស់ឈ្មោះ [redacted] **ដារ៉ូ** ដែលគាត់បានយកទៅជាមួយ។ បន្ទាប់មកសមត្ថកិច្ចបានឃាត់ខ្លួន និងឈ្មោះ [redacted] **ដារ៉ូ**។ ខ្លួនស្គាល់ឈ្មោះ [redacted] **ដារ៉ូ** ប្រហែល ០២ ទៅ ០៣ឆ្នាំមកហើយ។ ខ្លួនបានដឹកឈ្មោះ [redacted] **ដារ៉ូ** ទៅដើរបិណ្ឌបាតចំនួន ២លើក គឺនៅថ្ងៃទី០២ និងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣។ ដំបូងឈ្មោះ [redacted] **ដារ៉ូ** បានខលមករកខ្លួនឱ្យជួយ ដឹកគាត់ទៅដើរបិណ្ឌបាតនៅម្តុំផ្សារឃ្លាំងលើ ពេលខ្លួនទៅដឹកគាត់នៅម្តុំចំណោទយាយម៉ៅគាត់បានស្លៀកពាក់ស្បង់ចីពរនៅលើកងបីរបស់ខ្លួន ដោយគាត់ដើរបិណ្ឌបាតចាប់ពីម៉ោង ៨ ទៅម៉ោង ១០ព្រឹក។ ពេលដើរបិណ្ឌបាតរួច គាត់បានហៅខ្លួនទៅយកគាត់



Scanned with CamScanner

វិញ។ ឈ្មោះ [redacted] ដារ៉ូ បានឱ្យថ្លៃឈ្នួលខ្លួន ០១ថ្ងៃ ចំនួន ៥ម៉ឺនរៀល ថ្ងៃដឹកគាត់។ ក្រៅពីឈ្មោះ [redacted] ដារ៉ូ ខ្លួនមិនដែលដឹកអ្នកផ្សេងដែលក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតទេ។ ចំពោះឈ្មោះ [redacted] វ៉ាន់ថា, ឈ្មោះ [redacted] ឃីម និងឈ្មោះ [redacted] ភ័កក្ដី ខ្លួនមិនដែលស្គាល់ពីមុនមកទេ។ ពេលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតទូរស័ព្ទ ០១គ្រឿង ម៉ាក MI ពណ៌ស និងកងបីចំនួន០១គ្រឿង គ្មានផ្លាកលេខ។

**សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ**

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ៖ ក្រោយពីបានសួរដេញដោល និងភស្តុតាងនានាឃើញថា ជនជាប់ចោទឈ្មោះ [redacted] ឃីម ភេទប្រុស, ឈ្មោះ [redacted] ភ័កក្ដី ហៅ នីត ភេទប្រុស, ឈ្មោះ [redacted] វ៉ាន់ថា ហៅ វីរៈ ភេទប្រុស, ឈ្មោះ [redacted] ដារ៉ូ ឬ [redacted] ដារ៉ូ ហៅ ពៅ ភេទប្រុស និងឈ្មោះ [redacted] រស្មី បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ១៣២ អ.យ.ង/២៤ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ និងស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្ដន្ទាទោសជនជាប់ចោទខាងលើតាមច្បាប់។

**សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា ៖ កូនក្ដីរបស់ខ្លួនទាំងអស់សុទ្ធតែបានឆ្លើយសារភាព និងទទួលស្គាល់កំហុសរបស់ខ្លួន ដែលបញ្ជាក់ថា កូនក្ដីខ្លួនមានការភ្ញាក់រលឹក និងមានការកែប្រែខ្លួន ដោយមិនធ្វើសកម្មភាពប្រព្រឹត្តអំពើល្មើសតទៅទៀត។ ជាងនេះទៅទៀតចំពោះកូនក្ដីខ្លួនឈ្មោះ [redacted] ភ័កក្ដី ហៅ នីត ជាអនីតិជនដោយមិនមានការគិតគូរបានវែងឆ្ងាយ ជាងនេះទៅទៀតអ្វីដែលពួកគេបានប្រព្រឹត្តគឺដោយសារតែមិនមានការយល់ដឹង និងដោយសារតែមានជីវភាពខ្វះខាត និងជីដូនជីតាមានជម្ងឺប្រចាំកាយ ទើបជម្រុញឱ្យកូនក្ដីខ្លួនធ្វើសកម្មភាពខាងលើ។ ទោះជាយ៉ាងណាក៏ដោយជនជាប់ចោទដឹងកំហុស និងភ្ញាក់រលឹក ហេតុនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទគប្បីស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ និងសម្រេចដោយផ្ដល់ស្ថានសម្រាលចំពោះកូនក្ដីខ្លួនផង ព្រោះពួកគាត់សុទ្ធតែជាបង្គោលគ្រួសារ និងចាំបាច់ត្រូវរកការងារដើម្បីយកប្រាក់មកផ្គត់ផ្គង់គ្រួសារ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ**

-ជនជាប់ចោទឈ្មោះ [redacted] ឃីម បាននិយាយសំដីចុងក្រោយថា៖ ស្នើសុំតុលាការបន្ធូរបន្ថយទោស។

-ជនជាប់ចោទឈ្មោះ [redacted] ភ័កក្ដី ហៅ នីត បាននិយាយសំដីចុងក្រោយថា៖ ស្នើសុំតុលាការបន្ធូរបន្ថយទោស។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ថា ហៅ វីរៈ បាននិយាយសំដីចុងក្រោយថា៖ ស្នើសុំតុលាការបន្ធូរបន្ថយទោស។

-ជនជាប់ចោទឈ្មោះ [redacted] ដារ៉ូ ឬ [redacted] ដារ៉ូ ហៅ ពៅ បាននិយាយសំដីចុងក្រោយថា៖ ស្នើសុំតុលាការបន្ធូរបន្ថយទោស។

-ជនជាប់ចោទឈ្មោះ [redacted] រស្មី បាននិយាយសំដីចុងក្រោយថា៖ ស្នើសុំតុលាការបន្ធូរបន្ថយទោស។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១-ដោយសាររឿងក្ដីអនីតិជន តុលាការត្រូវដំណើរការការពិភាក្សាដេញដោលជាអសាធារណៈ ស្របតាមមាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៥៧ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ។

២-កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១០និង ៣០នាទីព្រឹក នៅចំនុចភូមិសាស្ត្រក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុពិតជាមានករណី **ស្លៀកដណ្ដប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ(ក្លែងធ្វើព្រះសង្ឃ) និងឆបោក** មួយបង្កឡើងដោយឈ្មោះ [redacted] ឃីម, ឈ្មោះ [redacted] ភ័កក្ដី ហៅ នីត, ឈ្មោះ [redacted] វ៉ាន់ថា ហៅ វីរៈ, ឈ្មោះ [redacted] ដារ៉ូ



Scanned with CamScanner

ឬ [redacted] ដារ៉ូ ហៅ ពៅ និងឈ្មោះ [redacted] វស្នី។ ដោយឈ្មោះ [redacted] ដារ៉ូ ឬ [redacted] ដារ៉ូ ហៅ ពៅ និងឈ្មោះ [redacted] លៀក (ជាអនីតិជនអាយុ ១២ឆ្នាំ) បានស្លៀកពាក់ក្លែងខ្លួនជាព្រះសង្ឃដើរបិណ្ឌបាតបច្ច័យពីពុទ្ធបរិស័ទក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយមានឈ្មោះ [redacted] វស្នី ជាអ្នកដឹកពួកគេទាំង ០២នាក់ ក្នុងមួយថ្ងៃបានថ្លៃឈ្នួលចំនួន ៥០,០០០ (ប្រាំម៉ឺន)រៀល។ ចំណែកឯឈ្មោះ [redacted] យើម, ឈ្មោះ [redacted] វ៉ាន់ថា ហៅ វីរៈ និងឈ្មោះ [redacted] ភ័ក្តី ហៅ ទីត បានធ្វើសកម្មភាពស្លៀកពាក់ក្លែងខ្លួនធ្វើជាព្រះសង្ឃដើរបិណ្ឌបាតបច្ច័យពីពុទ្ធបរិស័ទនៅក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដូចគ្នា ដោយឈ្មោះ [redacted] យើម បានជួលម៉ូតូកង់បីមួយគ្រឿង ដើម្បីធ្វើជាមធ្យោបាយក្នុងការធ្វើដំណើរ។ លុះដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ ប្រជាពលរដ្ឋរាយការណ៍ជូនសមត្ថកិច្ចធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនជនជាប់ចោទខាងលើព្រមទាំងដកហូតបានវត្ថុតាងមួយចំនួន រួមមាន ម៉ូតូកង់បីឥណ្ឌាចំនួន ០១គ្រឿង, អាវកាក់ណោក(ហង្សាក់) ចំនួន ០៧, ស្បង់ចីពរ ចំនួន ០៧, ថង់យាម ចំនួន ០៧, ឆត្រ ចំនួន ០៧, បាតលោក ចំនួន ០៥, កាបូបស្ពាយពណ៌ខ្មៅ ចំនួន ០១, កាបូបដៃបុរសពណ៌ខ្មៅចំនួន ០២, ប្រាក់ចំនួន ២០៥,០០០រៀល និងទូរស័ព្ទដៃចំនួន ០៥គ្រឿង។

៣-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] យើម, ឈ្មោះ [redacted] ភ័ក្តី ហៅ ទីត, ឈ្មោះ [redacted] វ៉ាន់ថា ហៅ វីរៈ, ឈ្មោះ [redacted] ដារ៉ូ ឬ [redacted] ដារ៉ូ ហៅ ពៅ និងឈ្មោះ [redacted] វស្នី, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងកំណត់ហេតុចាប់យកវត្ថុតាង មានលក្ខណៈស៊ីសង្វាក់នឹងរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ជាភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់អាចឱ្យតុលាការពិចារណាសម្រេចបាន។

៤-ពិនិត្យលើសកម្មភាពរបស់ជនជាប់ចោទឃើញថា ជនជាប់ចោទឈ្មោះ [redacted] យើម, ឈ្មោះ [redacted] ភ័ក្តី ហៅ ទីត, ឈ្មោះ [redacted] វ៉ាន់ថា ហៅ វីរៈ និងឈ្មោះ [redacted] ដារ៉ូ ឬ [redacted] ដារ៉ូ ហៅ ពៅ ពិតជាបានធ្វើសកម្មភាព **ស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ(ក្លែងធ្វើព្រះសង្ឃ)** ដើម្បីដើរបិណ្ឌបាតក្នុងក្រុងព្រះសីហនុ ដោយពួកគេជាជនស៊ីវិល និងមិនមែនជាព្រះសង្ឃពិប្រាកដ ក្នុងចេតនាទទួលបានប្រាក់ជាប្រយោជន៍ផ្ទាល់ខ្លួន ដោយទទួលបានប្រាក់ក្នុង ០១ ថ្ងៃពី ៦ម៉ឺនរៀល ទៅ ១០ម៉ឺនរៀល។ ដែលសកម្មភាពរបស់ជនជាប់ចោទជាចារីខាងលើគឺជាការប្រព្រឹត្តដោយចេតនានូវបទល្មើស **អាចារ** និងបទ **ស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៧៧**, មាត្រា **៣៧៨** និងមាត្រា **៥០៨** នៃក្រមព្រហ្មទណ្ឌ។ រីឯសកម្មភាពរបស់ឈ្មោះ [redacted] វស្នី ជាអ្នកស៊ីឈ្នួលដឹកពួកគេ និងទទួលបានថ្លៃឈ្នួលចំនួន ៥ម៉ឺនរៀល ក្នុង ០១ថ្ងៃ ស្តែងចេញជាអ្នកសមគំនិតក្នុងបទល្មើស **អាចារ** និងបទ **ស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៩**, មាត្រា **៣៧៧**, មាត្រា **៣៧៨** និងមាត្រា **៥០៨** នៃក្រមព្រហ្មទណ្ឌ។

៥-នាពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទឈ្មោះ [redacted] ដារ៉ូ ឬ [redacted] ដារ៉ូ ហៅ ពៅ គឺជាអនីតិជន មានអាយុលើសពី ១៤ឆ្នាំ និងជាជនមានស្មារតីគ្រប់គ្រាន់ និងសមត្ថភាពពេញលេញក្នុងការយល់ដឹងពីអំពើរបស់ខ្លួន និងលទ្ធផលតាមផ្លូវច្បាប់ ដូច្នេះជនជាប់ចោទអាចទទួលខុសត្រូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់បាន។

៦-នាពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទឈ្មោះ [redacted] យើម, ឈ្មោះ [redacted] ភ័ក្តី ហៅ ទីត, ឈ្មោះ [redacted] វ៉ាន់ថា ហៅ វីរៈ និងឈ្មោះ [redacted] វស្នី គឺជានីតិជន ជាជនមានស្មារតីគ្រប់គ្រាន់ និងសមត្ថភាពពេញលេញក្នុងការយល់ដឹងពីអំពើរបស់ខ្លួន និងលទ្ធផលតាមផ្លូវច្បាប់ ដូច្នេះជនជាប់ចោទអាចទទួលខុសត្រូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់បាន។

៧-អំពើដែលជនជាប់ចោទឈ្មោះ [redacted] យើម, ឈ្មោះ [redacted] ភ័ក្តី ហៅ ទីត, ឈ្មោះ [redacted] វ៉ាន់ថា ហៅ វីរៈ, ឈ្មោះ [redacted] ដារ៉ូ ឬ [redacted] ដារ៉ូ ហៅ ពៅ និងឈ្មោះ [redacted] វស្នី បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ព្រមទាំងប៉ះពាល់ដល់ព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ហើយច្បាប់បញ្ញត្តិថាបទល្មើសព្រហ្មទណ្ឌដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] យើម, ឈ្មោះ [redacted] ភ័ក្តី ហៅ ទីត, ឈ្មោះ [redacted] វ៉ាន់ថា ហៅ វីរៈ និងឈ្មោះ [redacted] ដារ៉ូ ឬ [redacted] ដារ៉ូ ហៅ ពៅ ពីបទ **អាចារ** និងបទ **ស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៧៧**, មាត្រា **៣៧៨** និងមាត្រា **៥០៨** នៃក្រមព្រហ្មទណ្ឌ។ រីឯឈ្មោះ [redacted] វស្នី **ជាជនសមគំនិតក្នុងអំពើអាចារ** និង **អំពើស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៩**, មាត្រា **៣៧៧**, មាត្រា **៣៧៨**,



Scanned with CamScanner

និងមាត្រា **៥០៨** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣។

**៩**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន នៅតែរក្សាការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ **១៣២** អ.យ.ង/២៤ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ ដដែល។ ការស្នើសុំនេះមានសំអាងគ្រប់គ្រាន់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

**១០**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ជនជាប់ចោទ ព្រោះកូនក្តីខ្លួនបានឆ្លើយសហការណ៍ដោយពុំបង្កភាពលំបាកដល់តុលាការក្នុងការវិនិច្ឆ័យសេចក្តី។ ដែលនេះបញ្ជាក់ឱ្យឃើញថា កូនក្តីរបស់ខ្លួនបានដឹងកំហុសរបស់ខ្លួន និងបង្ហាញឱ្យឃើញថា ពួកគាត់បានកែប្រែខ្លួន។ ចំពោះការស្នើសុំ និងសំអាងរបស់មេធាវីនេះ តុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

**១១**-ជនជាប់ចោទឈ្មោះ [redacted] **ឃីម**, ឈ្មោះ [redacted] **ភ័កក្តី** ហៅ **នីត**, ឈ្មោះ [redacted] **វ៉ាន់ថា** ហៅ **វីរៈ**, ឈ្មោះ [redacted] **ដារ៉ូ** ឬ [redacted] **ដារ៉ូ** ហៅ **ពៅ** និងឈ្មោះ [redacted] **វស្សី** បាននិយាយសំដីចុងក្រោយថាសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង គប្បីតុលាការពិចារណា។

**១២**-វត្ថុតាងរួមមាន ៖ ម៉ូតូកង់បីឥណ្ឌាចំនួន ០១គ្រឿង, អាវកាក់លោក(ហង្សាក់) ចំនួន ០៧, ស្បង់ចីពរចំនួន ០៧, ថង់យាម ចំនួន ០៧, ឆត្រ ចំនួន ០៧, បាតលោក ចំនួន ០៥, កាបូបស្ពាយពណ៌ខ្មៅ ចំនួន ០១, កាបូបដៃបុរសពណ៌ខ្មៅចំនួន ០២, ប្រាក់ចំនួន ២០៥,០០០រៀល និងទូរស័ព្ទដៃចំនួន ០៥គ្រឿង ជាសម្ភារៈដែលជនជាប់ចោទប្រើជាមធ្យោបាយប្រព្រឹត្តបទល្មើស និងជាផលនៃបទល្មើស។ គប្បីតុលាការសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា **៣៨២** នៃក្រមព្រហ្មទណ្ឌ។

**១៣**-ជនជាប់ចោទឈ្មោះ [redacted] **ភ័កក្តី** ហៅ **នីត** ជាអនីតិជន គប្បីពិចារណាសម្រាលទោសតាមបញ្ញត្តិមាត្រា **១៦០** នៃក្រមព្រហ្មទណ្ឌ។

**១៤**-ពិនិត្យឱ្យបានដិតដល់ជនជាប់ចោទទើបប្រព្រឹត្តបទល្មើសលើកដំបូង ខ្វះការយល់ដឹង បានសំដែងការស្មោះត្រង់ និងមានស្មារតីភ្ញាក់រលឹកដឹងកំហុសរបស់ខ្លួន ហើយការប្រព្រឹត្តបទល្មើសគ្រាន់បានជាកម្រៃតិចតួចក្នុងការផ្គត់ផ្គង់គ្រួសារប៉ុណ្ណោះ គប្បីតុលាការពិចារណាផ្តល់ស្ថានសម្រាលទោស។

## សេចក្តីសម្រេច

**១**- ផ្តន្ទាទោសលើ ៖

**១.១**- ឈ្មោះ [redacted] **ឃីម** ភេទប្រុស អាយុ ២៤ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ

**១.២**- ឈ្មោះ [redacted] **វ៉ាន់ថា** ហៅ **វីរៈ** ភេទប្រុស អាយុ ២៤ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ

**១.៣**- ឈ្មោះ [redacted] **ដារ៉ូ** ឬ **តូច ដារ៉ូ** ហៅ **ពៅ** ភេទប្រុស អាយុ ២៤ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ

**១.៤**- ឈ្មោះ [redacted] **វស្សី** ភេទប្រុស អាយុ ២២ឆ្នាំ កើតឆ្នាំ២០០១ ជនជាតិខ្មែរ

ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេល **០៨ (ប្រាំបី)ខែ** តែទោសនេះអនុវត្តទោសពន្ធនាគារចំនួន **០៤ (បួន)ខែ** ទោសសល់ពីនេះត្រូវព្យួរធម្មតា

**១.៥**- ឈ្មោះ [redacted] **ភ័កក្តី** ហៅ **នីត** ភេទប្រុស អាយុ ១៤ឆ្នាំ កើតឆ្នាំ២០០៩ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល **០៤ (បួន)ខែ**

ពីបទ **ឆបោក** និងបទ **ស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ** ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៧៧**, មាត្រា **៣៧៨** និងមាត្រា **៥០៨** នៃក្រមព្រហ្មទណ្ឌ។

**២**-វត្ថុចាប់យករួមមាន ៖ ម៉ូតូកង់បីឥណ្ឌាចំនួន ០១គ្រឿង, អាវកាក់លោក(ហង្សាក់) ចំនួន ០៧, ស្បង់ចីពរចំនួន ០៧, ថង់យាម ចំនួន ០៧, ឆត្រ ចំនួន ០៧, បាតលោក ចំនួន ០៥, កាបូបស្ពាយពណ៌ខ្មៅ ចំនួន ០១, កាបូបដៃបុរសពណ៌ខ្មៅចំនួន ០២, ប្រាក់ចំនួន ២០៥,០០០រៀល និងទូរស័ព្ទដៃចំនួន ០៥គ្រឿង ត្រូវរឹបអូស។

**៣**-ការពិភាក្សាដេញដោលនៅក្នុងសវនាការត្រូវប្រព្រឹត្តទៅជាអសាធារណៈ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ និងប្រកាសនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ឃើម**, ឈ្មោះ [redacted] **ភ័កក្តី** ហៅ **នីត**, ឈ្មោះ [redacted] **វ៉ាន់ថា** ហៅ **វីរៈ**, ឈ្មោះ [redacted] **ដារ៉ូ** ឬ **ឡូច ដារ៉ូ** ហៅ **ពៅ** និងឈ្មោះ [redacted] **រស្មី**។

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**ថ្ងៃព្រហស្បតិ៍ ១១រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧**

**ខេត្តព្រះសីហនុ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤**

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

[redacted]



Scanned with CamScanner